Moral Civic Education - NIE

តើអ្វីដែលខ្ញុំ
ត្រូវបង្រៀន ?

# របៀបសរសេរ
# កិច្ចតែងការបង្រៀន



តើខ្ញុំត្រូវ
បង្រៀនដោយ
របៀបណា ?

ណែនាំឱ្យស្គាល់មូលដ្ឋានគ្រឹះក្នុងការរៀបចំ
កិច្ចតែងការបង្រៀន និងគន្លឹះក្នុងការសរសេរ
កិច្ចតែងការបង្រៀនដ៏ល្អមួយ

តើខ្ញុំបង្រៀន
អ្នកណា ?



តើខ្ញុំអាចដឹង
ថាសិស្សខ្ញុំយល់
ដោយរបៀប
ណា ?


NW
NE
W
E
SW
SE
S

# កិច្ចតែងការបង្រៀន



## តើអ្វីជាកិច្ចតែងការបង្រៀន ?

- ជាផែនការ ឬការព្រាងទុកជាមុននូវគំនិតសំខាន់ៗមុននឹងឡើងបង្រៀនមេរៀន
- ជាជំនួយស្មារតីរបស់គ្រូបង្រៀន ដោយហេតុថាលំនឹករបស់មនុស្សតែងតែមានការខ្វះចន្លោះ ឬបាត់បង់ទៅវិញខ្លះទៅតាមវេលាដែលយើងទុកចោល វាមិនអាចលេចឡើងភ្លាមៗគ្រប់កាលៈទេសៈដែលយើងត្រូវការឡើយ ។
- ដូច្នេះការកត់ត្រាទុក ឬការព្រាងទុកជាមុនវាជារឿងចាំបាច់ណាស់ ដើម្បីឱ្យការបង្រៀនមានប្រសិទ្ធភាព មិនច្របូកច្របល់ និងបាត់បង់ភាពម្ចាស់ការក្នុងពេលបង្រៀនសិស្ស ។

# តើកិច្ចតែងការបង្រៀនមានសារៈសំខាន់ដូចម្តេចខ្លះ?



- ជំនួយស្មារតីប្រុងប្រយ័ត្នរបស់គ្រូបង្រៀន
- គោរពតាមជំហានទាំង៥
- ខ្លឹមសារមេរៀនត្រូវអនុវត្តតាមកម្មវិធី និងកាលវិភាគកំណត់របស់ក្រសួងអប់រំ យុវជននិងកីឡា
- មានការបម្រុងជាមុននូវសកម្មភាពដែលត្រូវបង្រៀនតាមលំដាប់លំដោយគួបផ្សំនឹងការរៀបចំសម្ភារឧបទេសឱ្យបានស៊ីសង្វាក់
- បង្កើនល្បិច និងរៀបចំវិធីសាស្ត្របង្រៀនបានល្អ
- ជួយជាលំដាប់គំនិតនៃការរៀបចំមេរៀន និងការបង្កើតសំណួរ
- ចៀសវាងការបង្រៀនមិនចប់ គ្មានលំដាប់លំដោយ និងការភ្លេចកន្លែងណាមួយដែលនាំឱ្យអសកម្មក្នុងពេលបង្រៀន
- ដើម្បីក្លាយជាគ្រូបង្រៀនល្អ

# តើត្រូវវិភាគលើចំណុចណាខ្លះមុននឹងសរសេរកិច្ចតែងការបង្រៀន?



- ពិនិត្យកម្មវិធីសិក្សា
- កាលវិភាគ
- អាន(សៀវភៅសិស្ស សៀវភៅគ្រូ ឯកសារពាក់ព័ន្ធ)
- ខ្លឹមសារមេរៀន
- សម្ភារឧបទេស

# តើត្រូវវិភាគលើចំណុចណាខ្លះមុននឹងសរសេរកិច្ចតែងការបង្រៀន?



**បរិស្ថានសិក្សា**
- នៅក្នុងថ្នាក់រៀន
- ក្រៅថ្នាក់៖ ទីធ្លា/បន្ទប់ពិសោធន៍/រោងជាង/ក្នុងសួន
- ក្រៅសាលារៀន៖ ទីសាធារណៈ រោងចក្រ រមណីយដ្ឋាន

**វត្ថុបំណង**
- វិជ្ជាសម្បទា
- បំណិនសម្បទា
- ចរិយាសម្បទា

# តើត្រូវវិភាគលើចំណុចណាខ្លះមុននឹងសរសេរកិច្ចតែងការបង្រៀន?



តើសិស្សធ្វើអ្វី? តាមវិធីណា?

គ្រូធ្វើសកម្មភាព អ្វី? តាមវិធីណា?

សកម្មភាព សិក្សា

# តើត្រូវវិភាគលើចំណុចណាខ្លះមុននឹងសរសេរកិច្ចតែងការបង្រៀន?





# តើត្រូវវិភាគលើចំណុចណាខ្លះមុននឹងសរសេរកិច្ចតែងការបង្រៀន?





# ផ្នែកសំខាន់ៗនៃកិច្ចតែងការបង្រៀន



- ចំណងជើងជំពូក និងមេរៀន
- វត្ថុបំណង
- ខ្លឹមសារមេរៀន
- សម្ភារឧបទេស
- ដំនឹកនាំមេរៀន

# ចំណងជើងជំពូក និងមេរៀន



- មុខវិជ្ជា : សីលធម៌ពលរដ្ឋវិជ្ជា
- ជំពូកទី១ : តម្លៃមនុស្ស
- មេរៀនទី១ : បញ្ញា
- រយៈពេល : ២ ម៉ោង
- បង្រៀនថ្នាក់ : ១២ C

# វត្ថុបំណង



**និយមន័យ:** វត្ថុបំណងគឺជាការកំណត់ទុកនូវអ្វីដែលយើងចង់បានក្រោយពីឆ្លងកាត់សកម្មភាពបង្រៀន និងរៀន ។

- **វិជ្ជាសម្បទា (ចំណេះដឹង)(Knowledge):** ជាបញ្ញត្តិ ព័ត៌មានដែលសិស្សទទួលបាន ។ ក្នុងការកំណត់វត្ថុបំណងលើចំណេះដឹង គ្រូត្រូវសង្កត់ធ្ងន់លើ **សកម្មភាព លក្ខខណ្ឌ ស្តង់ដា** ។
- **បំណិនសម្បទា (បំណិន) (Skill):** គឺជាការអនុវត្តចំណេះដឹង ការហ្វឹកហាត់ ប្រតិបត្តិ គណនា បកស្រាយ បត់បែន ទៅតាមស្ថានភាពជាក់ស្តែង ។ ក្នុងបំណិនក៏ត្រូវមាន **សកម្មភាព លក្ខខណ្ឌ ស្តង់ដា** ។
- **ចរិយាសម្បទា (ឥរិយាបថ)(Attitude) :** គឺជាការប្រែប្រួលអាកប្បកិរិយា ស្មារតីដែលមានលក្ខណៈជាបុគ្គល និងសង្គមក្រោយពីសិក្សារួច ។

# វត្ថុបំណង



- **សកម្មភាព** (Action):សកម្មភាពត្រូវអនុវត្តដើម្បីទទួលបានចំណេះដឹង ។ ជាអំពើឬកាយវិការដែលអ្នកសិក្សាត្រូវតែធ្វើដោយខានពុំបានដើម្បីសម្រេចគោលដៅ ។
- **លក្ខខណ្ឌ** (Condition):គឺជាមធ្យោបាយ និងដែនកំណត់យើងប្រើប្រាស់ក្នុងពេលបង្រៀន និងរៀន ។
- **កម្រិតលទ្ធផល** (Standard):គឺជាការកំណត់ទំហំ ឬបរិមាណនៃលទ្ធផល ដែលសិស្សនឹងទទួលបាន ហើយអាចវាស់បានពិតប្រាកដ ។

# វត្ថុបំណង



- ឧទាហរណ៍ វត្ថុបំណង មេរៀន "បរិស្ថាន"

| សមត្ថភាព | សកម្មភាព | លក្ខខណ្ឌ | កម្រិត លទ្ធផល |
| --- | --- | --- | --- |
| ចំណេះដឹង | សិស្សរៀបរាប់ពីអ្វីដែលនៅជុំវិញខ្លួន | តាមរយៈអត្ថបទ ឬ រូបភាព | បានត្រឹមត្រូវយ៉ាងតិច ៧0% |
| បំណិន | សិស្សឱ្យនិយមន័យបរិស្ថានបាន | តាមរយៈសកម្មភាពជាក្រុម | បានត្រឹមត្រូវ |
| ឥរិយាបថ | សិស្សចូលរួមសម្អាតនិងថែរក្សាផ្ទះ សាលារៀន | តាមរយៈសកម្មភាពជាបុគ្គល/ ក្រុម | |

# វត្ថុបំណង



កិរិយាស័ព្ទដែលច្បាស់លាស់ និងអាចវាស់វែងបាន
ប្រើនៅក្នុងវិជ្ជាសម្បទាទាំងបី

| | សកម្មភាព | កម្រិតលទ្ធផល | លក្ខខណ្ឌ |
|---|---|---|---|
| **ចំណេះសម្បទា** | -រៀបរាប់<br>-ពណ៌នា<br>-កំណត់<br>-បង្ហាញ<br>-និយាយ<br>-ប្រាប់ | -បានត្រឹមត្រូវ<br>-បានច្បាស់លាស់<br>-បានក្បោះក្បាយ<br>-បានស៊ីជម្រៅ | -តាមរយៈ<br>-ដោយផ្អែកលើ<br>-ដោយផ្តើមចេញពី<br>-ដោយអនុវត្តតាម<br>-ដោយយកគំរូតាម |
| **បំណិនសម្បទា** | -រៀបចំ<br>-បកស្រាយ<br>-បែងចែក<br>-វែកញែក<br>-ប្រើប្រាស់<br>-ប្រាប់<br>-ស្វែងយល់<br>-ពិភាក្សា<br>-ជ្រើសរើស<br>-បង្ហាញ<br>-កំណត់ | -បានត្រឹមត្រូវ<br>-បានច្បាស់លាស់<br>-បានក្បោះក្បាយ<br>-បានស៊ីជម្រៅ | -តាមរយៈ<br>-ដោយផ្អែកលើ<br>-ដោយផ្តើមចេញពី<br>-ដោយអនុវត្តតាម<br>-ដោយយកគំរូតាម |
| **ចរិយាសម្បទា** | -ទទួលស្គាល់<br>-បណ្តុះស្មារតី<br>-ថែរក្សា<br>-ចូលរួម<br>-យកចិត្តទុកដាក់<br>-មានទំនួលខុសត្រូវ<br>-វិភាគ<br>-មានស្មារតី<br>-ស្រឡាញ់<br>-ចាត់ទុក<br>-ការពារ<br>-ប្រកាន់ខ្ជាប់ | -បានត្រឹមត្រូវ<br>-បានច្បាស់លាស់<br>-បានក្បោះក្បាយ<br>-បានស៊ីជម្រៅ<br>-ជាប្រចាំ | -តាមរយៈ<br>-ដោយផ្អែកលើ<br>-ដោយផ្តើមចេញពី<br>-ដោយអនុវត្តតាម<br>-ដោយយកគំរូតាម |

ខ្លឹមសារមេរៀន
រូបភាព
ឧទាហរណ៍
ការពិភាក្សា
ពិសោធន៍
ប្រតិបត្តិ
សំណួរបំផុស
សំណួរពិភាក្សា
អនុវត្តផ្ទាល់
ទស្សនកិច្ចសិក្សា

Moral Civic Education-NIE

# ខ្លឹមសារមេរៀន



- ជាខ្លឹមដែលបង្ហាញត្រង់និងបង្កប់ក្នុងមេរៀន ដែលគ្រូត្រូវស្វែងយល់ឱ្យបានច្បាស់ និងរកឱ្យឃើញ ចំណេះដឹង បំណិន ឥរិយាបថ ដើម្បីបណ្ដុះបណ្ដាលសិស្សឱ្យទទួលបាន ។ វាជាចំណុចសំខាន់ដែលត្រូវកំណត់ឱ្យបានច្បាស់លាស់តាមម៉ោងបង្រៀននីមួយៗ ។

តើក្នុងមេរៀនមានខ្លឹមសារសំខាន់អ្វីខ្លះដែលត្រូវផ្ដល់ឱ្យសិស្ស ?

គួរបន្ថែមខ្លឹមសារខ្លះទៀតឬទេ ? ព្រោះអ្វី ? តាមវិធីណា ?

គួរបន្ថយខ្លឹមសារណាខ្លះ ?

# ខ្លឹមសារមេរៀន



➢ គ្រូត្រូវវិភាគរកឱ្យឃើញថា នៅក្នុងខ្លឹមសារមេរៀននេះ៖

តើសិស្សចេះអ្វីខ្លះហើយ ?

តើអ្វីខ្លះដែលសិស្សមិនទាន់ចេះ ?

តើអ្វីខ្លះដែលទាមទារឱ្យសិស្សចេះ ដើម្បីឈានទៅចាប់ចំណេះថ្មីបាន ?

ចំណេះចាស់ + ខ្លឹមសារដែលគ្រូបញ្ចូលដើម្បីជាឈ្នាន់ចាប់យក → ចំណេះថ្មី

# ខ្លឹមសារមេរៀន



ដើម្បីការបង្រៀនមួយកាន់តែសុក្រឹត គ្រូបង្រៀនគប្បីគិតអំពី៖

- ១ ខ្លឹមសារក្នុងសៀវភៅសិស្ស និងសៀវភៅគ្រូ
- ២ ខ្លឹមសារមេរៀនផ្សេង ៗ ដែលទាក់ទងនឹងមេរៀននេះ
- ៣ សមត្ថភាពមានស្រាប់ និងសមត្ថភាពចាំបាច់សិស្ស
- ៤ ស្ថានភាពមូលដ្ឋានដែលសិស្សរស់នៅ
- ៥ ការបន្ថែម ឬបន្ថយខ្លឹមសារខ្លះ ដើម្បីសម្រេចកម្មវិធីសិក្សា

# សម្ភារឧបទេស






- ជាអ្វីដែលគ្រូត្រូវប្រើប្រាស់សម្រាប់បង្រៀន និងរៀន ដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែច្បាស់ ហើយងាយយល់ ។
- វាអាចជាសម្ភារៈងាយៗរកបាន សម្ភារច្នៃប្រឌិត ដូចជា៖ សៀវភៅសិស្ស សៀវភៅគ្រូ រូបភាព រូបថត ប័ណ្ណសំណួរ ឧបករណ៍ពិសោធ .... សម្ភារចាំបាច់ដទៃទៀតសមស្របតាមមេរៀន ។











# ផលប្រយោជន៍សម្ភារឧបទេស



- ធ្វើឱ្យការបង្រៀនប្រព្រឹត្តទៅបានល្អ បង្កើតរូបារម្មណ៍ បង្កើតគំនិតថ្មី ងាយស្រួលក្នុងការបង្រៀន និងរៀន
- ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត
- ធ្វើអ្វីដែលអរូបី ឱ្យមានលក្ខណៈរូបី
- ពង្រឹងចំណេះដឹង បណ្តុះស្មារតីសិស្ស
- ធ្វើឱ្យថ្នាក់រៀនមានលក្ខណៈសកម្ម និងភាពរស់រវើក ដោយសិស្សបានសង្កេតជាក់ស្តែង វិភាគ សំយោគដោយខ្លួនឯង
- វាជាវិធីធ្វើឱ្យសិស្សចងចាំបានយូរ និងមានចំណូលចិត្តក្នុងការសិក្សា ។
- ដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែច្បាស់និងងាយយល់

# សកម្មភាពសិក្សា



- ជាការត្រៀមសកម្មភាពរបស់សិស្ស និងគ្រូក្នុងលំនាំនៃការបង្រៀន ។
- សកម្មភាពសិស្ស និងសកម្មភាពគ្រូជាកត្តាកំណត់លទ្ធផលនៃការបង្រៀន ។
- ការត្រៀមសកម្មភាពបានល្អ ជាក់ស្តែងអាចធ្វើឱ្យការបង្រៀន រៀន សម្រេចវត្ថុបំណងដែលបានកំណត់ ។



# ដំនឹកនាំមេរៀន ឬលំនាំនៃការបង្រៀន



- លំនាំនៃការបង្រៀនគឺជាសកម្មភាពជាបន្តបន្ទាប់ដែលត្រូវធ្វើដើម្បីឱ្យសម្រេចវត្ថុបំណងនៃមេរៀន ក៏ដូចជាប្រសិទ្ធភាពនៃការបង្រៀន និងរៀន ដែលមាន៥ជំហាន ។

1. **ជំហានទី១**
   រដ្ឋបាលថ្នាក់ ឬ លំនឹងថ្នាក់
2. **ជំហានទី២**
   រំលឹកមេរៀនចាស់
3. **ជំហានទី៣**
   មេរៀនប្រចាំថ្ងៃ
4. **ជំហានទី៤**
   ពង្រឹងពុទ្ធិ
5. **ជំហានទី៥**
   បណ្ដាំផ្ញើ

# ជំហានទី១ ៖ រដ្ឋបាលថ្នាក់ ឬ លំនឹងថ្នាក់





# ជំហានទី១ ៖ រដ្ឋបាលថ្នាក់ ឬ លំនឹងថ្នាក់



+ ជាសកម្មភាពដែលគ្រូត្រូវធ្វើជាចាំបាច់ដូចជា

- ពិនិត្យអវត្តមាន
- ពិនិត្យអនាម័យ
- ពង្រឹងវិន័យ និងសណ្តាប់ធ្នាប់ថ្នាក់រៀន ។

+ ក្នុងជំហាននេះមើលទៅសាមញ្ញ ប៉ុន្តែវាបានបង្កប់អត្ថន័យសំខាន់មួយនោះគឺ ការប្រមូលអារម្មណ៍អ្នកសិក្សា(សិស្ស) ឱ្យវិលមកយកចិត្តទុកដាក់ចំពោះការ សិក្សា(ដល់ម៉ោងចូលរៀនហើយ) ។

# ជំហានទី២ ៖រំលឹកមេរៀនចាស់



- សួរសំណួរផ្ទាល់មាត់ ឬសរសេរ ដើម្បីបញ្ជាក់ការចងចាំ ឬ កែកិច្ចការចាស់ ជាបុគ្គល ឬសមូហភាព
- បំផុសសមត្ថភាពមានស្រាប់ និងសមត្ថភាពចាំបាច់ ដើម្បីភ្ជាប់មេរៀនចាស់ទៅមេរៀនថ្មី ។



# ជំហានទី៣ ៖ មេរៀនប្រចាំថ្ងៃ



- ពណ៌នារូបភាព

-គ្រូណែនាំសិស្សពិនិត្យចំនុចសំខាន់ៗដោយចោទសួរទាក់ទងទៅនឹងរូបភាព

-សិស្សសង្កេតរូបភាពរួចឆ្លើយសំណួររបស់គ្រូ




- ការស្វែងយល់ខ្លឹមសារមេរៀន

-សិស្សអានអត្ថបទមេរៀនសម្រាប់ថ្ងៃនេះ
ហើយកត់ចំណាំចំណុចសំខាន់ៗ

- សំនួរបញ្ជាក់ការយល់ខ្លឹមសារមេរៀន

-ពន្យល់ពាក្យពិបាក (ប្រសិនបើមាន)

-គ្រូចោទសំណួរ ទាក់ទងនឹងមេរៀនដែលសិស្សបានអានរួច ដើម្បីស្វែងយល់ខ្លឹមសារមេរៀន ។

# ជំហានទី៣ ៖ មេរៀនប្រចាំថ្ងៃ



- គ្រូអាច



-រៀបចំសិស្សជាក្រុមតូច ឬក្រុមធំ

-រៀបចំកន្លែងសម្រាប់ពិភាក្សា

-ផ្តល់សំណួរសម្រាប់បុគ្គលអនុវត្ត ឬពិភាក្សាក្រុម

-ផ្តល់សម្ភារៈឧបទេស ឬបង្ហាញសម្ភារឧបទេស

-រៀបចំប័ណ្ណសំណួរសម្រាប់សិស្សអនុវត្ត

-តាមដានការពិភាក្សា

-បំភ្លឺសិស្សពេលមានបញ្ហា, សំយោគ កែលម្អ ចម្លើយសិស្ស និងលើកទឹកចិត្តសិស្ស... ។

**ចំណាំៈ សកម្មភាពទាំងនេះ គឺគ្រូអាចជ្រើសរើសមកប្រើតាមការចាំបាច់ មិនមែនប្រើគ្រប់សកម្មភាពទេ**

# ជំហានទី៣ ៖ មេរៀនប្រចាំថ្ងៃ



## ពិភាក្សាតាមក្រុម

- គ្រូបែងចែកសិស្សជាក្រុមពិភាក្សាទៅតាមចំនួនសំនួរដែលមាន (មួយក្រុម ៤-៥នាក់ ដោយចាត់ម្នាក់ធ្វើជាតំណាងក្រុម និងម្នាក់ធ្វើជាលេខាកត់ត្រា)
- គ្រូសរសេរសំណួរលើក្ដារខៀន ឬចែកសំណួរឱ្យតាមក្រុម ឬឱ្យសិស្សមើលសំណួរនៅក្នុងសៀវភៅសិស្ស
- សិស្សពិភាក្សាប្ដូរយោបល់ គ្រូត្រូវជួយពិនិត្យតាមក្រុមនីមួយៗដើម្បីឱ្យប្រាកដថាសិស្សយល់ពីសំណួរ និងកំពុងជជែកគ្នាទាក់ទងនឹងមេរៀន ។
- តំណាងក្រុមនីមួយៗឡើងរាយការណ៍លើក្ដារខៀន ។
- គ្រូជួយកែសម្រួល ចម្លើយ ហើយឱ្យសិស្សកត់ចម្លើយសំណួរពិភាក្សាចូលសៀវភៅរៀងៗខ្លួន





# ជំហានទី៤ ៖ ពង្រឹងពុទ្ធិ ឬវង្វាយតម្លៃ



- វត្ថុបំណងនៃវង្វាយតម្លៃគឺវាស់ស្ទង់សមត្ថភាពរបស់សិស្សក្រោយពេលបញ្ចប់មេរៀន ថាតើបានសម្រេចដល់វត្ថុបំណងដែលបានកំណត់ឬទេ ? ហើយក៏វាបង្ហាញឱ្យឃើញពីសមត្ថភាពនៃការបង្រៀនរបស់គ្រូដែរ ។
- តើនៅក្នុងវង្វាយតម្លៃ គ្រូត្រូវព្រាងអ្វីខ្លះ ?

សំណួរផ្ទាល់មាត់ជាបុគ្គល ឬជាក្រុម

សំណួរសរសេរ

ប្រើប័ណ្ណសំណួរ ឬធ្វើពិសោធន៍...



# ជំហានទី៥៖ បណ្តាំផ្ញើ ឬ សកម្មភាពបន្ថែម



- គ្រូដាក់កិច្ចការផ្ទះ
- គ្រូអាចផ្តាំផ្ញើឱ្យសិស្សមើលមេរៀនឡើងវិញ ឬអានមេរៀនបន្ត សម្រាប់ម៉ោងក្រោយ
- កិច្ចការសម្រាប់បំពេញកង្វះខាតពេលបង្រៀនក្នុងថ្នាក់

# កិច្ចការផ្ទះ ឬបណ្តាំផ្ញើ



## តើគ្រូត្រូវត្រៀមគំនិតអ្វីខ្លះ ?

+ **ផ្តល់កិច្ចការឱ្យសិស្សសម្រាប់អនុវត្តនៅផ្ទះ**
  - កិច្ចការសម្រាប់បំពេញកង្វះខាតពេលបង្រៀនក្នុងថ្នាក់
  - កិច្ចការសម្រាប់ពង្រីកចំណេះដឹងបន្ថែម
  - កិច្ចការសម្រាប់ឱ្យស្រាវជ្រាវ ដើម្បីបម្រើឱ្យមេរៀនក្រោយ
  - កិច្ចការសម្រាប់សិស្សខ្សោយ ឬពូកែ ។
+ **បណ្តាំផ្ញើផ្សេង ៗ**
  - ត្រៀមមេរៀនក្រោយ និងត្រៀមសម្ភារឧបទេសសម្រាប់មេរៀនក្រោយ... ។

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១**<br>(០៣នាទី) | រដ្ឋបាលថ្នាក់ | រាយការណ៍ |
| **ជំហានទី២**<br>(០៧នាទី) | ក.រំលឹកមេរៀនចាស់<br>ខ.ឃ្លាភ្ជាប់មេរៀនថ្មី | ✓ សិស្សឆ្លើយ<br>✓ យកចិត្តទុកដាក់ |
| **ជំហានទី៣**<br>(២៥-៣០នាទី) | មេរៀនប្រចាំថ្ងៃ | ✓ អានមេរៀន<br>✓ ពិនិត្យរូបភាព<br>✓ ឆ្លើយសំណួរ<br>✓ ពិភាក្សាក្រុម<br>✓ ស្តាប់ កត់ត្រាមេរៀន |
| **ជំហានទី៤**<br>(០៧នាទី) | ពង្រឹងចំណេះដឹង | ✓ សិស្សឆ្លើយ |
| **ជំហានទី៥**<br>(០៣នាទី) | បណ្តាំផ្ញើ (កិច្ចការផ្ទះ) | ✓ ស្តាប់អនុវត្តតាម<br>✓ កត់កិច្ចការផ្ទះ |

Moral Civic Education-NIE

# សន្និដ្ឋាន



- លទ្ធផលនៃការបង្រៀន និងរៀន អាស្រ័យមួយផ្នែកធំលើការរៀបចំ**កិច្ចតែងការបង្រៀន** ។
- កិច្ចតែងការបង្រៀនល្អ គឺកិច្ចតែងការដែលបានកំណត់វត្ថុបំណងច្បាស់លាស់ ខ្លឹមសារគ្រប់គ្រាន់ប្រកបដោយលក្ខខណ្ឌធ្វើកម្មភាពសមស្រប ។
- គ្រូបង្រៀន ត្រូវរៀបចំកិច្ចតែងការបង្រៀនជា3កូឡោន 5ជំហាន ព្រោះវាអាចជួយឱ្យមានការងាយស្រួលក្នុងការ កំណត់ខ្លឹមសារ និងសកម្មភាពដែលគ្រូ និងសិស្សត្រូវអនុវត្តនៅពេលបង្រៀន ៕

# គំរូកិច្ចតែងការបង្រៀន

| **កិច្ចតែងការបង្រៀន** | | |
|---|---|---|
| - មុខវិជ្ជា | : | សីលធម៌ពលរដ្ឋវិជ្ជា |
| - ជំពូកទី ១ | : | តម្លៃមនុស្ស |
| - មេរៀនទី១ | : | ការច្នៃប្រឌិត |
| - រយៈពេល | : | ២ម៉ោង (**ម៉ោងទី១**) |
| - បង្រៀនថ្នាក់ | : | ទី ១០ A |
| - កាលបរិច្ឆេទ | : | ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| វិធីសាស្ត្របង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល | | |

## កិច្ចតែងការបង្រៀនសម្រាប់រយៈពេល ១ ម៉ោង

**I. វត្ថុបំណង**

- **វិជ្ជាសម្បទា** : ប្រាប់បានច្បាស់លាស់ពីអត្ថន័យ និងសារប្រយោជន៍នៃគំនិតច្នៃប្រឌិតតាមរយៈខ្លឹមសារមេរៀន ។
- **បំណិនសម្បទា** : ជ្រើសរើសនូវឧទាហរណ៍ផ្សេងៗពីគំនិតច្នៃប្រឌិតបានសមស្របដោយផ្អែកលើសំនួរបំផុស ។
- **ចរិយាសម្បទា** : ទទួលស្គាល់គំនិតច្នៃប្រឌិតពិតជាមានសារៈប្រយោជន៍សម្រាប់អភិវឌ្ឍខ្លួនទៅអនាគតតាមរយៈសំនួរពិភាក្សា ។

**II. ខ្លឹមសារមេរៀន**

ការច្នៃប្រឌិត និង គំនិតច្នៃប្រឌិត

**III. សម្ភារឧបទេស**

✓ សៀវភៅសិក្សាសង្គម (សីលធម៌ពលរដ្ឋវិជ្ជា) ថ្នាក់ទី១០ ទំព័រទី ១៩៦ ដល់ ទំព័រទី១៩៧

✓ កិច្ចតែងការបង្រៀន

✓ ផ្ទាំងក្រដាស (វត្ថុបំណងមេរៀន និង ពន្យល់ពាក្យ)

✓ ប័ណ្ណសំណួរពិភាក្សាក្រុម

**IV. ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| -គ្រូត្រួតពិនិត្យ អនាម័យ និងសណ្តាប់ធ្នាប់សិស្ស<br>-សួរ និងស្តាប់ប្រធានថ្នាក់រាយការណ៍ពីអវត្តមាន | <u>ជំហានទី១</u>(០៣នាទី)<br>"លំនឹងថ្នាក់"<br>-ពិនិត្យអនាម័យ ឯកសណ្ឋាន<br>-ត្រួតពិនិត្យវត្តមានសិស្សក្នុងថ្នាក់<br>-ពង្រឹងវិន័យ | -សិស្សក្រោកឈរ ឬស្វាគមន៍គ្រូ<br>-ប្រធានថ្នាក់ឡើងរាយការណ៍ពីអវត្តមានសិស្សក្នុងថ្នាក់ |
| គ្រូសួរសំនួរ<br>- សប្តាហ៍មុនយើងជួបគ្នាលើកទីមួយ តើប្អូនចាំទេយើងបានពិភាក្សាគ្នាពីបញ្ហាអ្វីខ្លះ ?<br><br>ឃ្លាភ្ជាប់សេចក្តី<br>......ថ្ងៃនេះយើងរៀននឹងចាប់រៀន មេរៀនថ្មីសម្រាប់ដើមឆ្នាំសិក្សានេះ គឺ.............. | <u>ជំហានទី២</u>(០៧នាទី)<br>"រំលឹកមេរៀនចាស់"<br>- ស្គាល់គ្នាទៅវិញទៅមក<br>- បទបញ្ញាតិក្នុងថ្នាក់រៀន<br>- គម្រោងការមេរៀន<br>- របៀបធ្វើការវាយតម្លៃ (ដាក់ពិន្ទុ)<br><br>**ការវិវត្តប្រឌិត** | - ណែនាំខ្លួន និងណែនាំពីគោលបំណងទៅអនាគត<br>- បង្កើតវិន័យក្នុងថ្នាក់<br>- បង្ហាញពីរបៀបដាក់ពិន្ទុ<br>- បង្ហាញពីវិធីផ្សេងៗដែលប្រើក្នុងការបង្រៀន ។<br><br>សិស្សស្តាប់ដោយយកចិត្តទុកដាក់ |

| | | |
|---|---|---|
| | **<u>ជំហានទី៣</u>**(៣០នាទី)<br>"មេរៀនប្រចាំថ្ងៃ" | |
| -គ្រូសរសេរកាលបរិច្ឆេទ និង សរសេរចំណងជើងមេរៀន ដាក់លើក្តាខៀន | <u>ជំពូកទី១</u> : " **តម្លៃមនុស្ស** "<br><u>មេរៀនទី១</u> : " **ការច្នៃប្រឌិត** " | -សិស្សចម្លងចំណងជើងដាក់ចូលសៀវភៅសរសេររបស់ខ្លួន |
| -បិទវត្ថុបំណងមេរៀន ហើយឱ្យ សិស្សម្នាក់អានវត្ថុបំណងនៃមេរៀន | • ផ្តើមសេចក្តី | -សិស្សអាន |
| -សរសេរពន្យល់ពាក្យលើក្តាខៀន ហើយឱ្យសិស្សសាកល្បង រកអត្ថន័យរបស់ពាក្យទាំងនោះ | **ពន្យល់ពាក្យ**<br>១. ច្នៃ (កិ.) = លៃលកឲ្យបានស្រួលឲ្យល្អឡើង កែសម្រួល ។<br>២. ប្រឌិត ឬប្រតិដ្ឋ (កិ.) = បង្កើតឲ្យមានតាមយោបល់របស់ខ្លួនដោយប្រដូចទៅនឹងនេះនឹងនោះ ខុសសោះក៏មាន ត្រូវដែរក៏មាន ។<br>៣. សមត្ថភាព (ន) = ភាពនៃសេចក្តីអាចហ៊ាន សេចក្តីមុះមុត ។ល។ | -សិស្សឆ្លើយ និងកត់ត្រា<br>- សិស្សអាចសួរពីពាក្យពិបាកផ្សេងៗទៀត |
| - ចូរប្អូនរកឧទាហរណ៍អំពីសម្ភារច្នៃប្រឌិតថ្មីៗក្នុងប្រទេសកម្ពុជា ឬក្នុងភូមិរបស់ប្អូន ។ | - ឧទាហណ៍មួយចំនួនអំពីសម្ភារច្នៃប្រឌិតក្នុងស្រុក | - សិស្សរកឧទាហរណ៍៖ ម៉ាស៊ីនបោកស្រូវ រឺម៉ក...... |
| *ចែកសិស្សជាបីក្រុមពិភាក្សា*<br>- សរសេរសំណួរដាក់លើក្តារខៀន | **១.ការច្នៃប្រឌិត**<br>**១.១.គំនិតច្នៃប្រឌិត**<br>សំនួរពិភាក្សាក្រុម<br>- បំណែងចែកក្រុម៖ ក្នុងក្រុមនីមួយៗត្រូវមានប្រធានសម្របសម្រួល លេខាកត់ត្រា អ្នកឡើងបកស្រាយ និងសមាជិក | សិស្សចូលតាមក្រុម |

| | | |
|---|---|---|
| **ក្រុមទី១៖** តើគំនិតច្នៃប្រឌិតមានអត្ថន័យដូចម្តេច? | ចំ.១. គំនិតច្នៃប្រឌិតសំដៅយកគំនិតផ្តួចផ្តើមធ្វើអ្វីមួយ បង្កើតអ្វីមួយឲ្យលេចជារូបរាង និងអាចប្រើប្រាស់តាមតម្រូវការរបស់ខ្លួន ។ | **តំណាងក្រុមទី១**<br>ចំ.១.គំនិតច្នៃប្រឌិតសំដៅយកគំនិតផ្តួចផ្តើមធ្វើអ្វីមួយ បង្កើតអ្វីមួយឲ្យលេចជារូបរាង និងអាចប្រើប្រាស់តាមតម្រូវការរបស់ខ្លួន ។ |
| **ក្រុមទី២៖** តើគំនិតច្នៃប្រឌិតផ្តល់ផលប្រយោជន៍អ្វីខ្លះដល់គ្រួសារ និងសង្គម? | ចំ.២. ផ្តល់ផលប្រយោជន៍ដូចជា៖<br>- មានសម្ភារៈប្រើប្រាស់ដែលមានតម្លៃសមរម្យ<br>- កាត់បន្ថយការនាំចូលពីបរទេស<br>- បង្កើតការងារដល់ប្រជាជនក្នុងស្រុក<br>- បណ្តុះបណ្តាលវិជ្ជាជីវៈជំនាញពង្រីកសម្ថភាព ទេពកោសល្យ បទពិសោធន៍ដល់ប្រជាជន<br>- ជម្រុញឲ្យសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិមានការរីកចម្រើន ។ | **តំណាងក្រុមទី២**<br>ចំ.២. ផ្តល់ផលប្រយោជន៍ដូចជា៖<br>- មានសម្ភារៈប្រើប្រាស់ដែលមានតម្លៃសមរម្យ<br>- កាត់បន្ថយការនាំចូលពីបរទេស<br>- បង្កើតការងារដល់ប្រជាជន<br>- បណ្តុះបណ្តាលវិជ្ជាជីវៈជំនាញពង្រីកសម្ថភាព ទេពកោសល្យ បទពិសោធន៍ដល់ប្រជាជន<br>- ជម្រុញឲ្យសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិមានការរីកចម្រើន ។ |
| **ក្រុមទី៣៖** តើដើម្បីឲ្យគំនិតច្នៃប្រឌិតរបស់ខ្លួនអាចទទួលបានភាពជោគជ័យបុគ្គលម្នាក់ៗគួរគិតលើកត្តាអ្វីខ្លះ? | ចំ.៣. ត្រូវគិតលើកត្តា៖<br>- ព្យាយាម ប្រឹងប្រែង អត់ធ្មត់ស្រាវជ្រាវ<br>- មានជំនឿជឿជាក់លើខ្លួនឯង<br>- ប្រកាន់ខ្ជាប់ភាពត្រឹមត្រូវ<br>- ឆ្ពោះទៅរកគំនិតថ្មី សម្ភារសំបូរបែប<br>- ចូលរួមអភិវឌ្ឍប្រទេសផងដែរ ។ | **តំណាងក្រុមទី៣**<br>ចំ.៣. ត្រូវគិតលើកត្តា៖<br>- ព្យាយាម ប្រឹងប្រែង អត់ធ្មត់ស្រាវជ្រាវ<br>- មានជំនឿជឿជាក់លើខ្លួនឯង<br>- ប្រកាន់ខ្ជាប់ភាពត្រឹមត្រូវ<br>- ឆ្ពោះទៅរកគំនិតថ្មី សម្ភារសំបូរ<br>- ចូលរួមអភិវឌ្ឍប្រទេសផងដែរ |
| *គ្រូជួយសម្របសម្រួលចម្លើយ*<br>+ ករណីសិស្សរកចម្លើយពុំបានពេញលេញ គ្រូសួរសំនួរបំផុសគំនិតដើម្បីបានចម្លើយពេញលេញ ។ | +សំនួរបំផុសគំនិតដើម្បីបានចម្លើយពេញលេញ | +សិស្សឆ្លើយបំពេញបន្ថែម និងចម្លងចូលសៀវភៅសរសេរ |

| | | |
|---|---|---|
| - គ្រូសួរសំនួរ<br>១៖ តើគំនិតច្នៃប្រឌិតមានអត្ថន័យដូចម្តេច?<br><br>២៖តើប្រឌិត ឬប្រិតដ្ឋមានអត្ថន័យដូចម្តេច? | <u>**ជំហានទី៤**</u>(៧នាទី)<br>**"ពង្រឹងពុទ្ធិ"**<br>ចំ.១. គំនិតច្នៃប្រឌិតសំដៅយកគំនិតផ្តួចផ្តើមធ្វើអ្វីមួយ បង្កើតអ្វីមួយឲ្យលេចជារូបរាង និងអាចប្រើប្រាស់តាមតម្រូវការរបស់ខ្លួន ។<br>ចំ.២. ប្រឌិត ឬប្រតិដ្ឋ (កិ.) = បង្កើតឲ្យមានតាមយោបល់របស់ខ្លួនដោយប្រដូចទៅនឹងនេះនឹងនោះ ខុសសោះក៏មាន ត្រូវដែរក៏មាន ។ | -សិស្សឆ្លើយ<br>ចំ.១. គំនិតច្នៃប្រឌិតសំដៅយកគំនិតផ្តួចផ្តើមធ្វើអ្វីមួយ បង្កើតអ្វីមួយឲ្យលេចជារូបរាង និងអាចប្រើប្រាស់តាមតម្រូវការរបស់ខ្លួន ។<br>ចំ.២. ប្រឌិត ឬប្រតិដ្ឋ (កិ.) = បង្កើតឲ្យមានតាមយោបល់របស់ខ្លួនដោយប្រដូចទៅនឹងនេះនឹងនោះខុសសោះក៏មានត្រូវដែរក៏មាន |
| -គ្រូធ្វើការផ្តាំផ្ញើដល់សិស្សឲ្យ៖<br>. អានមេរៀនរហូតចប់<br><br>.ដាក់កិច្ចការផ្ទះ<br>សំ. មូលហេតុអ្វីបានជាគេផ្តល់ការលើកទឹកចិត្ត ឬរង្វាន់ដល់អ្នកមានគំនិតច្នៃប្រឌិត និងរបកគំហើញថ្មី? | <u>**ជំហានទី៥**</u> (០៣នាទី)<br>**"បណ្តាំផ្ញើ"**<br>*ទំព័រ១៩៨-១៩៩*<br>1.2 គំនិតបង្កើតថ្មី<br>2. គោលការណ៍ក្នុងការអភិវឌ្ឍគំនិតច្នៃប្រឌិត<br><br>សំនួរទី៤ក្នុងសៀវភៅសិស្សទំព័រ១៩៩ | -សិស្សស្តាប់ និង<br><br>-កត់ត្រាកិច្ចការផ្ទះដាក់ចូលសៀវភៅរៀង ៗ ខ្លួន |